ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ១០៣/២៤ ក.ប/ស.ណ.ត.ខ.ល

# សេចក្តីណែនាំ
## ស្តីពី
## ការវាយគង ជួង រគាំង ទូងស្គរ ទះប៉ោត និងគោះត្រដោកនៅតាមសហគ្រាស គ្រឹះស្ថាន ដើម្បីអបអរសាទរការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ

ដើម្បីចូលរួមអបអរសាទរការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ ដែលជា "**គម្រោងរបស់ខ្មែរទាំងអស់គ្នា ដោយខ្មែរ និងដើម្បីខ្មែរគ្រប់រូប**" និងផ្តល់ផលប្រយោជន៍ដ៏មហាសាលដល់សង្គម-សេដ្ឋកិច្ចកម្ពុជា ជាពិសេសជាមរតកប្រវត្តិសាស្ត្រសម្រាប់កូនចៅជំនាន់ក្រោយរបស់យើងទាំងអស់គ្នា ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤ ខាងមុខនេះ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវត្រៀមលក្ខណៈ និងអនុវត្ត ដូចខាងក្រោម៖

**១-ថ្ងៃទី៣ ឬថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៤៖**

- ចាត់តាំងបុគ្គលិកផ្នែករដ្ឋបាល ដើម្បីរៀបចំ និងសម្របសម្រួលពិធីអបអរសាទរ
- កំណត់ទីតាំងសមស្របនៃសហគ្រាស គ្រឹះស្ថាន ដែលអាចប្រមូលផ្តុំកម្មករនិយោជិត ដើម្បីរៀបចំពិធី
- រៀបចំឧបករណ៍សម្រាប់ចាក់ផ្សាយបន្តផ្ទាល់ពីទស្សនីយភាពនៃការបើកការដ្ឋានសាងសង់ និងតេស្តឧបករណ៍បំពងសម្លេងដែលមានក្នុងសហគ្រាស គ្រឹះស្ថានស្រាប់
- រៀបចំឧបករណ៍ ដូចជា គង ជួង រគាំង ស្គរ ប៉ោត និងត្រដោក តាមគ្រប់មធ្យោបាយដែលខ្លួនមាន ដើម្បីបន្លឺសម្លេងឱ្យបានកងរំពង
- ជូនដំណឹងដល់បងប្អូនកម្មករនិយោជិតទាំងអស់អំពីទីតាំង និងរំហូរនៃការរៀបចំពិធីអបអរសាទរនៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤។

**២-ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤៖**

- ម៉ោង ៧:២០នាទីព្រឹក៖ ចាក់ផ្សាយបន្តផ្ទាល់ជាសម្លេង ពីទស្សនីយភាពនៃការបើកការដ្ឋានសាងសង់ នៅតាមខ្សែចង្វាក់ផលិតកម្ម និងនៅទីតាំងដែលរោងចក្របានកំណត់ ដើម្បីឱ្យបងប្អូនកម្មករនិយោជិតបានស្តាប់នូវប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤៣៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- ម៉ោង ៨:៣០នាទីព្រឹកៈ រៀបចំឱ្យបងប្អូនកម្មករនិយោជិតទាំងអស់ចូលដល់ទីតាំងដែលបានកំណត់ និងចាត់បុគ្គលិកឱ្យត្រៀមវាយឧបករណ៍ដែលបានត្រៀមទុក សម្រាប់ចូលរួមពិធីអបអរសាទរ
- ម៉ោង ៩:០៩នាទីព្រឹកៈ រួមគ្នាវាយគង ជួង រគាំង ទូងស្គរ ទះប៉ោត និងគោះត្រដោក តាមគ្រប់មធ្យោបាយដែលខ្លួនមាន ឱ្យបានព្រមៗគ្នា។

អាស្រ័យដូចបានជម្រាបជូនខាងលើ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងបងប្អូនកម្មករនិយោជិតទាំងអស់ ត្រូវចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្ដីណែនាំនេះប្រកបដោយទឹកចិត្តមោទនៈ និងផ្សព្វផ្សាយនូវសកម្មភាពចូលរួមអបអរសាទរព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះឱ្យបានផុលផុស។

ថ្ងៃសុក្រ ៣ រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល**:

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-ក្រសួង ស្ថាប័នពាក់ព័ន្ធ

-មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈរាជធានី ខេត្ត

-ឯកសារ កាលប្បវត្តិ